# អរិយធម៌ចិនបុរាណ

ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា ចិនជាប្រទេសដែលមានផ្ទៃដីធំ និងមានប្រជាជនច្រើនជាងគេបង្អស់នៅលើពិភពលោក ហើយចិនក៏ជាប្រទេសដែលមានអរិយធម៌ចំណាស់មួយក្នុងចំណោមអរិយធម៌ចំណាស់ៗទាំង៤លើពិភពលោក ដែលក្នុងនោះមានដូចជា មេសូប៉ូតាមី អេហ្ស៊ីប ឥណ្ឌុស និងចិន ។ តឹកតាងនៃការតាំងទីរស់នៅរបស់មនុស្សនៅលើទឹកដីនៃប្រទេសនេះ គឺមានតាំងពីយុគថ្មរំលីងមកម៉្លេះ។ ការជ្រើសរើសតាំងទីនៅតាមតំបន់ទន្លេនេះ គឺមិនមែនចៃដន្យនោះទេ គឺស្របទៅតាមវិស័យកសិកម្មនេសាទ និងការចិញ្ចឹមសត្វ ដែលមនុស្សពឹងផ្អែកទៅលើប្រភពទឹកជាសំខាន់។

អរិយធម៌ចិនបានរីកចម្រើននៅតាមបណ្តោយទន្លេពីរ គឺទន្លេលឿង និងទន្លេ Yangtze ប្រមាណ៣០០០ឆ្នាំមុនគ.ស. និងជាអរិយធម៌ដែលគ្រប់ដណ្តប់ផ្ទៃដីធំជាងគេបង្អស់ក្នុងចំណោមបណ្តាអរិយធម៌ផ្សេងៗទៀត[១] ហើយក៏មានក្រុមជនជាតិភាគតិចៗផ្សេងៗគ្នារស់នៅលើទឹកដីប្រទេសនេះ (រូបលេខ១)។ នៅរវាងស.វ.ទី២មុនគ.ស. ចិនគឺជាអាណាចក្រមួយដែលមមាញឹកទៅនឹងការជួញដូរផ្សេងៗជាមួយនឹងបណ្តាប្រទេសនៅតំបន់អាស៊ីកណ្តាល អាស៊ីខាងបូព៌ាជាដើម ដែលបានបង្កើតជាបណ្តាញផ្លូវពាណិជកម្មមួយហៅថា ផ្លូវសូត្រ (Silk Roads) ដោយការជួញដូរនោះ គឺជាការជួញដូររវាងវត្ថុធាតុដើម និងវត្ថុមានតម្លៃ ឬជាមួយផ្សេងៗទៀត។[២] អ្នកស្រាវជ្រាវបានបង្ហាញថាប្រទេសនេះមានអក្សរកត់ត្រាតាំងពីពាក់កណ្តាលស.វទី២មុនគ.ស ក្នុងរាជ្ជកាល Shang (១២០០-១០៥០មុនគ.ស.) ពោលគឺតាមរយៈការរកឃើញបំណែកឆ្អឹង នៅស្ថានីយ Yinxu ដែលជារាជធានី ក្នុងរាជ្ជកាល Shang (រូបលេខ៣)។ ឆ្អឹងដែលបានរកឃើញនោះប្រហែលជាបំណែកផ្នែកណាមួយនៃឆ្អឹងសត្វអ្វីដែលសំខាន់គឺឃើញមានអក្សរចារពីលើបំណែកឆ្អឹងទាំងនោះ។[៣]

---

[១] https://www.britannica.com : History of China

[២] https://whc.unesco.org: Silk Roads: the Routes Network of Chang'an-Tianshan Corridor

[៣] https://www.britannica.com: Chinese writing

អត្ថបទដោយ៖ អេង តុលា

នៅក្នុងប្រវត្តិសាស្ត្ររបស់ចិនការប្រើប្រាស់អក្សរទាំងនោះ គឺសម្រាប់ធ្វើការកត់ត្រារដ្ឋបាល រាល់សកម្មភាពតាម ថ្ងៃ ខែ និង ឆ្នាំ ដែលហៅថា កំណត់ត្រា (Chinese Annals)។[៤] នៅឆ្នាំ ១៩៧៥ មានការធ្វើកំណាយនៅក្នុងផ្នូរលេខ១១ ដែលស្ថិតក្នុងខេត្ត Hubei ដោយបានរកឃើញនូវកំណត់ត្រាដែលចារនៅលើ ឬស្សី ហៅថា Qin Bamboo of shuihudi ដែលស្ថិតនៅក្នុងរាជ្ជកាល Qin (២២១-២០៦មុនគ.ស.) ដោយក្នុងកំណាត់ត្រានោះបានបរិយាយអំពីច្បាប់ នយោបាយ នៅក្នុងរាជ្ជកាល Qin[៥] (រូបលេខ២៤)។ សំខាន់ជាងនេះផងដែរ អ្នកស្រាវជ្រាវបានរកឃើញទីតាំងផ្នូរកប់សពស្តេច Qinshihuang នៅខាងជើងភ្នំ Lishan ដែលមានចម្ងាយប្រមាណ៣៥គីឡូ ពីខេត្ត Shaanxi ដែលការរកឃើញនោះ គឺជារូបសំណាក់ទាហានដីដែលមានប្រមាណ៨០០០រូប បញ្ចុះជាមួយនឹងផ្នូរ ស្តេច Qinshihuang ដែលគេបានដឹងថា ជាអធិរាជ ក្នុងរាជ្ជកាល Qin (រូបលេខ២៥)។[៦]

ប្រជាជនចិនបុរាណមានបច្ចេកទេស និងគំនិតច្នៃប្រឌិតខ្ពស់ក្នុងការផលិតវត្ថុសិល្បៈតាមទម្រង់ផ្សេងៗដែលបានរកឃើញពីកន្លែងជាច្រើននៃអរិយធម៌នេះរួមមាន គ្រឿងស្មូនដីដូចជាកុលាលភាជន៍ Porcelain ប្រណិតៗ គ្រឿងអលង្ការ រូបចម្លាក់ដី អំពីថ្ម លោហៈធាតុ អំពីដីឥដ្ឋ និងជាពិសេសការកសាងសំណង់មហាកំពែងដែលវែងជាងគេនៅលើពិភពលោក (រូបលេខ២៦)។ ការប្រើប្រាស់នៃបច្ចេកទេសទាំងនោះ គឺមានតាំងពីយូរយាណាស់មកហើយ ពោលតាមរយៈការសិក្សាបុរាណលោហៈវិទ្យាលើវត្ថុលោហៈផ្សេងៗបានបង្ហាញថា ប្រទេសចិនបានបង្កើតបច្ចេកទេសស្មិតលោហៈធាតុដោយខ្លួនឯង ដែលមានអាយុកាលប្រហាក់ប្រហែលគ្នាជានឹងឥណ្ឌាដែរ ពោលរវាងឆ្នាំ១១០០មុនគ.ស. និងបច្ចេកទេសនោះក៏ឃើញមាននៅក្នុងប្រទេសកម្ពុជាសម័យបុរាណដែរ (រូបលេខ២៧)។[៧]

បើតាមរយៈការស្រាវជ្រាវផ្នែកបុរាណវិទ្យា មនុស្សដែលបានមកតាំងទីរស់នៅក្នុងទឹកដីប្រទេសនេះចាស់ជាង៣០០០ឆ្នាំមុនគ.ស. ទៅទៀត។ អ្នកស្រាវជ្រាវជនជាតិកាណាដាបានធ្វើកំណាយនៅឆ្នាំ១៩២៩ ក្នុងទីតាំងល្អាងភ្នំមួយកន្លែងដែលមានឈ្មោះ Zhoukoudian

---

[៤] អាចស្វែងរកបានក្នុង https://gallica.bnf.fr: Les annales de la chine

[៥] Zou Dahai ,2005.6: 57–65

[៦] https://whc.unesco.org: Mausoleum of the First Qin Emperor .

[៧] សូមអាន Bernard Dupaigne ‘’ La métallurgie dans l’ancien Cambodge’’, 1992

អត្ថបទដោយ៖ អេង តុលា

មានចំងាយប្រមាណ៤០គីឡូពីទីក្រុងបេកាំង បានរកឃើញផូសីលក្បាលមនុស្សដែលអ្នកស្រាវជ្រាវហៅថា បេកាំងមេន (Peking man) ស្ថិតនៅក្នុងអំបូរ អូមូ អេរិចទុស (Homo erectus) និងតាមរយៈការវិភាគធ្មេញនៃផូស៊ីលនោះ អាចមានអាយុកាលប្រមាណពី៦០០០០០ឆ្នាំ។[៨] ការហៅបេកាំងមេន បែបនេះគឺសំដៅលើការឃើញផូសីលនៃពូជមនុស្សនៅក្នុងទឹកដីប្រទេសចិន។

ទន្និន័យទាំងអស់ដែលបានបង្ហាញខាងលើនេះ អាចបង្ហាញឲ្យយើងឃើញអំពីតឹកតាំងនៃការតាំងទីរស់នៅរបស់មនុស្សនៅលើទឹកដីនៃប្រទេសនេះ គឺមានតាំងពីយុគថ្មរំលីងមកម៉្លេះ និងបង្ហាញពីអរិយធម៌នៃប្រទេសចិនមានការរីកចម្រើនខ្លាំងទាំងនយោបាយ សេដ្ឋកិច្ច និងបច្ចេកទេសក្នុងការផលិតវត្ថុសិល្បៈផ្សេងៗជាពិសេសកុលាលភាជន៍ Porcelain ដែលយើងក៏ឃើញមានវត្ថុមាននៅក្នុងប្រទេសកម្ពុជាសម័យបុរាណដែរ។

[៨] https://whc.unesco.org: Peking Man Site at Zhoukoudian




រូបលេខ១៖ ទន្លេ លឿន និងទន្លេ Yangtze

ប្រភព៖ https://www.yangtze-river-cruises.com




រូបលេខ២៖ បណ្តាញផ្លូវសូត្រ

ប្រភព៖ https://www.britannica.com

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៣៖ ឆ្អឹងសត្វរកឃើញនៅ Yinxu

ប្រភព៖ https://www.britannica.com



រូបលេខ២៤៖ កំណត់ត្រាឬស្សី Qin Bamboo

ប្រភព៖ Internet

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៥៖ រូបសំណាក់ទាហានដីដែលរកឃើញក្នុងផ្នូរស្តេច

ប្រភព៖ https://whc.unesco.org



រូបលេខ២៦៖ មហាកំពែង

ប្រភព៖ https://whc.unesco.org

អត្ថបទដោយ៖ អេង តុលា



រូបលេខ៧៖ Porcelain ក្នុងរាជ្យកាល Ming

ប្រភព៖https://whc.unesco.org



រូបលេខ៨៖ រូបក្បាលមនុស្សធ្វើពីសំរិទ្ធ

ប្រភព៖ https://whc.unesco.org

អត្ថបទដោយ៖ អេង តុលា



រូបលេខ៩៖ ផូស៊ីល Peking Man

ប្រភព៖ https://www.amnh.org




រូបលេខ១០៖ ធ្មេញដែលយកពីPeking Man យកធ្វើការវិភាគ

ប្រភព៖ Qian WANG, Li SUN, and Jan Ove R. EBBESTAD

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង


Bernard Dupaigne ,
1992 La métallurgie dans l’ancien Cambodge
Zou Dahai.
2005 Shuihudi’s Bamboo Strips of Qin Dynasty and Mathematics in Pre-Qin Period

https://www.britannica.com : History of China
https://whc.unesco.org: Silk Roads: the Routes Network of Chang'an-Tianshan Corridor
https://www.britannica.com: Chinese writing
https://gallica.bnf.fr: Les annales de la chine
https://whc.unesco.org: Mausoleum of the First Qin Emperor .


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION